# « អធិស្ឋានទៅ ហេលេមិន »



ដោយ ដេលលើ សៀលើ

( ផ្អែកទៅលើដំណើររឿងពិត )

វាជាថ្ងៃដំបូងរបស់ ហេលេមិន នៅឯសាលារៀន ។ គាត់បានពាក់អាវដែលគាត់ចូលចិត្តជាងគេ ហើយគាត់មានខ្មៅដៃថ្មីមួយ ។ គ្រូថ្មីរបស់របស់គាត់អនុញ្ញាតឲ្យគាត់អង្គុយនៅតុជាមួយមិត្តរបស់គាត់ឈ្មោះ ស៊ីលវ៉េស្ទើរ ហ៊ោហេ និង មីហ្គែល ។ វាជាថ្ងៃដ៏ល្អមួយ ។

អ្នកគ្រូ ម៉ាទីណេស បាននិយាយថា « រៀបចំកាតាបរបស់កូនៗទៅ ។ ដល់ពេលហូបបាយថ្ងៃហើយ » ។

គ្រួសាររបស់ ហេលេមិន តែងតែអធិស្ឋានរួមគ្នាជានិច្ច មុនពេលបរិភោគអាហារ ។ គាត់បានលើកដៃឡើង ។ « អ្នកគ្រូ ម៉ាទីណេស តើយើងនឹងអធិស្ឋានមុនពេលយើងហូបបាយទេ ? »

អ្នកគ្រូ ម៉ាទីណេស បានញញឹមដាក់ ហេលេមិន ។ « កូនអាចអធិស្ឋានសម្រាប់អាហាររបស់កូនបាន ប្រសិនបើកូនចង់អធិស្ឋាន » ។

ហេលេមិន និងមិត្តភក្តិរបស់គាត់បានបើកប្រអប់បាយថ្ងៃត្រង់របស់ពួកគេ ។

ស៊ីលវ៉េស្ទើរ បានសួរថា « តើការអធិស្ឋានជាអ្វីទៅ ? »

ហេលេមិន បានតបថា « វាគឺជាការទូលទៅកាន់ព្រះវរបិតាសួគ៌ ។ វាគឺជារបៀបដែលយើងអរព្រះគុណទ្រង់សម្រាប់អាហាររបស់យើង » ។

មីហ្គែល បានសួរថា « តើឯងអាចអធិស្ឋានសម្រាប់ពួកយើងទាំងអស់គ្នាបានទេ ? »

ហេលេមិន បានឱបដៃគាត់ ។ មិត្តទាំងបីរបស់គាត់បានឱបដៃរបស់ពួកគេដែរ ។ ហេលេមិនបានបិទភ្នែករបស់គាត់ ហើយបានឱនក្បាលចុះ ។ មិត្តរបស់គាត់ក៏បានធ្វើដូច្នោះដែរ ។

បន្ទាប់មក ហេលេមិនបានអធិស្ឋាន ដូចកាលគ្រួសាររបស់គាត់បានអធិស្ឋានដែរ ។ គាត់បានអរព្រះគុណព្រះវរបិតាសួគ៌សម្រាប់ថ្ងៃដ៏ល្អ ដែលពួកគេបានមាន និងសម្រាប់អាហារថ្ងៃត្រង់របស់ពួកគេ ។ គាត់បានសូមព្រះឲ្យប្រទានពរដល់អាហាររបស់ពួកគេ ។ គាត់បានបញ្ចប់នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយបាននិយាយថា « អាម៉ែន » ។



ស៊ីលវ៉េស្ទើរ ហ៊ោហេ និង មីហ្គែល បានងើបមុខឡើង ។

ហេលេមិន បាននិយាយថា « ពួកឯងក៏អាចនិយាយថា *អាម៉ែន* ផងដែរ » ។

មិត្តរបស់គាត់បានញញឹមស្ញេញ ហើយនិយាយថា « អាម៉ែន » ។

ស្អែកឡើងនៅម៉ោងបាយថ្ងៃត្រង់ ស៊ីលវ៉េស្ទើរ បាននិយាយថា « អធិស្ឋានទៅ ហេលេមិន » ។

មីហ្គែល បានបន្តថា « មែនហើយ អធិស្ឋានទៅ ហេលេមិន » ។ ហ៊ោហេ បានងក់ក្បាល ។

ដូច្នេះ ហេលេមិនបានអធិស្ឋានម្តងទៀត ។ លើកនេះ គាត់បាននិយាយថា គាត់មានអំណរគុណជាពិសេសដែលម៉ាក់របស់គាត់បានធ្វើសាំងវិចហេម និងឈីសដែលគាត់ចូលចិត្តឲ្យគាត់ ។ គាត់បានទូលសូមឲ្យព្រះវរបិតាសួគ៌ជួយពួកគេឲ្យរៀនក្នុងថ្នាក់នៅថ្ងៃនោះ ។

រាល់ថ្ងៃនៅពេលបាយថ្ងៃត្រង់ មិត្តរបស់ហេលេមិនបាននិយាយថា « អធិស្ឋានទៅ ហេលេមិន » ។ ហើយជារៀងរាល់ថ្ងៃ ហេលេមិនបានអធិស្ឋាន ។ គាត់បានអធិស្ឋានជាមួយមិត្តភក្តិរបស់គាត់រាល់ថ្ងៃពេញមួយសប្តាហ៍ ។

នៅថ្ងៃចន្ទក្រោយនៅម៉ោងបាយថ្ងៃត្រង់ មីហ្គែល បាននិយាយថា « ថ្ងៃនេះខ្ញុំនឹងអធិស្ឋាន » ។

ហេលេមិន មានការភ្ញាក់ផ្អើល ។ គាត់ឱបដៃរបស់គាត់ បិទភ្នែក ឱនក្បាលចុះ ហើយស្តាប់ កាលមីហ្គែល អធិស្ឋាន ។

មីហ្គែល បានចាប់ផ្តើមដោយពោលថា « ឱ ព្រះវរបិតាសួគ៌ជាទីស្រឡាញ់ » ។ គាត់បានអរព្រះគុណទ្រង់សម្រាប់អាហាររបស់ពួកគេ ហើយបានទូលសូមឲ្យទ្រង់ប្រទានពរដល់អាហារនោះ ។ គាត់បានបញ្ចប់នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយបាននិយាយថា « អាម៉ែន » ។

ហេលេមិន និង ហ៊ោហេ បាននិយាយថា « អាម៉ែន ! »

ស៊ីលវ៉េស្ទើរ បាននិយាយថា « អាម៉ែន » ។ « ខ្ញុំអត់ដឹងសោះថា ឯងចេះអធិស្ឋាន » ។

មីហ្គែល បាននិយាយថា « ខ្ញុំរៀនពេលស្តាប់ហេលេមិនអធិស្ឋាន ។ ខ្ញុំសូមប៉ាម៉ាក់ខ្ញុំថា តើខ្ញុំអាចអធិស្ឋានបានទេ ពេលយើងហូបបាយនៅផ្ទះ ។ ពួកគាត់ឆ្លើយថា បាន ដូច្នេះខ្ញុំអធិស្ឋានដូចជាហេលេមិនបានអធិស្ឋានដែរ » ។

ស៊ីលវ៉េស្ទើរ បាននិយាយថា « អស្ចារ្យមែន ។ ខ្ញុំគិតថា ខ្ញុំនឹងសូមប៉ាម៉ាក់ខ្ញុំដែរថា តើខ្ញុំអាចអធិស្ឋានពេលយើងហូបបាយបានឬអត់ » ។

ហ៊ោហេ បាននិយាយថា « ខ្ញុំក៏អីចឹងដែរ ! »

ហេលេមិនញញឹម ។ គាត់រីករាយណាស់ ដែលគាត់អាចជួយមិត្តភក្តិរបស់គាត់ឲ្យរៀនទូលជាមួយព្រះវរបិតាសួគ៌ ។ គាត់ដឹងថា ព្រះវរបិតាសួគ៌ស្រឡាញ់គាត់ ហើយព្រះវរបិតាសួគ៌ស្រឡាញ់មិត្តភក្តិរបស់គាត់ដែរ ។ ●

*រឿងនេះបានកើតឡើងនៅក្នុងប្រទេសម៉ិកស៊ិក ។*



